# បទសម្ភាសន៍ជាមួយសហព្រះរាជអាជ្ញាជាតិ លោកស្រី ជា លាង

***ម៉ៅ ឃើល សាលីបា និង ថៃ លើ នីមស៍***

***ថ្ងៃទី០២ ខែសីហា ឆ្នាំ២០១០***

*ប្រែសម្រួលដោយ គ្រី ស៊ុយហៀង កែសម្រួលដោយ ញាណ សុជាតិ*

*លោកស្រី ជា លាង គឺជាសហព្រះរាជអាជ្ញាជាតិនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ មុនពេលមានការតែងតាំងរបស់លោកស្រីនៅ អ.វ.ត.ក លោកស្រីបានបម្រើការជាព្រះរាជអាជ្ញានៅសាលាឧទ្ធរណ៍ ។ លោកស្រីក៏បានចូលរួមផងដែរនៅក្នុងការតាក់តែងសេចក្តីព្រាង នៃក្រមព្រហ្មទណ្ឌកម្ពុជា ខណៈពេលដែលលោកស្រីបម្រើការជាអនុប្រធានការិយាល័យបណ្តុះបណ្តាលនៃក្រសួងយុត្តិធម៌ ។ លោកស្រីទទួលបានសញ្ញាប័ត្រថ្នាក់អនុបណ្ឌិតផ្នែកច្បាប់នៅប្រទេសអាល្លឺម៉ង់ ហើយត្រូវបានតែងតាំងឲ្យបម្រើការជាអគ្គព្រះរាជអាជ្ញានៅតុលាការកំពូល ដែលជាមុខតំណែងតុលាការខ្ពស់បំផុតនៅក្នុងព្រះរាជណាចក្រកម្ពុជា ។ នៅថ្ងៃទី២ ខែសីហា ឆ្នាំ២០១០ លោកស្រី ជា លាង បានសំណេះសំណាលជាមួយអ្នកយកព័ត៌មានមកពីក្រុមឃ្លាំមើលតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម (CTM) ទាក់ទងនឹងការវិនិច្ឆ័យមកលើ ឌុច និងការវិវឌ្ឍផ្សេងៗរបស់ អ.វ.ត.ក ។*

CTM : *មានក្រុមជនរងគ្រោះ និងដើមបណ្តឹងរដ្ឋប្បវេណីជាច្រើនបានសម្តែងនូវការរិះគន់ទៅលើរយៈពេលនៃការកាត់ទោសនិងភាពដែលអាចទៅរួចដែលថាឌុចអាចនឹងចេញដើរដោយសេរី ម្តងទៀតបាន ។ ស្ថិតក្រោមច្បាប់កម្ពុជា ថាតើអាចមានឱកាសដែរឬទេដែលថា ឌុច ប្រហែលជាអាចទទួលបាននូវការដោះលែង មុនពេលការអស់សុពលភាពនៃរយៈពេលប្រហែល ១៩ឆ្នាំដែលគាត់ត្រូវជាប់គុកបន្តនោះ?*

*ជា លាង : ជាទស្សនៈរបស់សហព្រះរាជអាជ្ញា គឺថា ស្ថិតក្រោមច្បាប់ព្រហ្មទណ្ឌរបស់ប្រទេសកម្ពុជា បទបញ្ញត្តិនៃការដោះលែងមុនពេល មិនត្រូវបានយកមកអនុវត្តនៅក្នុងករណីរបស់ឌុចនោះទេ ។ នៅក្រោមច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងវិធានផ្ទៃក្នុងនោះ ព្រះរាជណាចក្រកម្ពុជាមិនត្រូវបានអនុញ្ញាតឲ្យលើកលែងទោស ឬដោះលែងឌុច ឲ្យរួចពីឃុំមុនពេលនោះទេ ។ ទស្សនៈនេះត្រូវបានយល់ស្របមុនពេលសាលក្រមត្រូវបានសម្រេចទៅទៀត ហើយក៏ត្រូវយកមកអនុវត្តលើចុងចោទដទៃទៀតនៅចំពោះមុខតុលាការផងដែរ ។*

CTM : នៅក្នុងទស្សនៈដែលមនុស្សជាច្រើនយល់ឃើញថាជាការកាត់ទោសធូរស្រាលនោះ តើខាងព្រះរាជអាជ្ញានឹងដាក់បណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមដែរឬទេ?

ជា លាង : យើងនៅមិនទាន់សម្រេចនៅឡើយទេថាតើនឹងដាក់បណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមនោះ ឥឡូវយើងកំពុងតែពិនិត្យឡើងវិញនូវអង្គហេតុ និងការរកឃើញផ្សេងៗនៅក្នុងការវិនិច្ឆ័យនោះ ហើយនឹងធ្វើការសម្រេចចិត្តជាក្រោយថាតើយើងនឹងប្រើប្រាស់សិទ្ធិរបស់យើងក្នុងការប្តឹងឧទ្ធរណ៍ដែរឬទេ ។

CTM : តើលោកស្រីមានគំនិតដូចគ្នាទៅនឹងទស្សនៈរបស់មេធាវីដើមបណ្តឹងរដ្ឋប្បវេណី ដែលថាសំណងដែលតុលាការផ្តល់ឲ្យនោះគឺតិចតួចឆ្ងាយណាស់?

ជា លាង : តុលាការមានសិទ្ធិផ្តល់សំណងជាសមូហភាព ។ នេះគឺជាតុលាការទីមួយក្នុងចំណោមប្រភេទតុលាការដូចគ្នានេះដែលធ្វើដូច្នោះ ហើយនេះបានផ្តល់នូវការលំបាកយ៉ាងខ្លាំងចំពោះទាំងខាងដើមបណ្តឹងរដ្ឋប្បវេណីនិងចៅក្រមផងដែរ ។ យើងអាចយល់បានថាខាងដើមបណ្តឹងរដ្ឋប្បវេណីមានអារម្មណ៍ថាពួកគេដូចជាមិនត្រូវបានផ្តល់ឲ្យគ្រប់គ្រាន់នោះទេ ប៉ុន្តែអំណាចរបស់ចៅក្រមគឺមានកម្រិត ។ ឥឡូវឧបមាថា ចៅក្រមបានផ្តល់ជាបូជនីយដ្ឋានមួយដើម្បីគោរពវិញ្ញាណក្ខន្ធជនរងគ្រោះ អ៊ីចឹងថាតើនរណានឹងផ្តល់ថវិកាដើម្បីសាងសង់នោះ? ជារដ្ឋាភិបាល, អង្គការក្រៅរដ្ឋាភិបាល ឬក៏អង្គភាពផ្សេងៗ? ម្យ៉ាងទៀត ប្រសិនបើរដ្ឋាភិបាលត្រូវបានតម្រូវឲ្យប្រតិបត្តិនូវសំណងនេះ ប៉ុន្តែរដ្ឋាភិបាលពុំមានថវិកានោះ ដូច្នេះតុលាការនឹងមិនមានយុត្តាធិការណា ឬក៏អំណាចក្នុងការបង្គាប់នូវសំណងនេះនោះទេ ។

CTM : ថាតើសាលក្រមប្រឆាំងនឹងឌុចនេះអាចនឹងជះឥទ្ធិពលដល់តុលាការក្នុងស្រុកដែរឬទេ?

ជា លាង : បើតាមទស្សនៈផ្នែកច្បាប់វិញ នេះគឺជាការវិនិច្ឆ័យមួយដ៏ល្អ ។ តុលាការមិនត្រឹមតែរកឃើញថាឌុចមានពិរុទ្ធភាពពីបទឧក្រិដ្ឋ ដែលត្រូវបានចោទប្រកាន់ទៅលើរូបគាត់នោះទេ ហើយថែមទាំងអាចការពារសិទ្ធិរបស់ឌុចទៀតផង ។ តួយ៉ាង តុលាការបានផ្តល់រង្វាន់ដល់គាត់ចំនួនប្រាំឆ្នាំសម្រាប់ការឃុំឃាំងមិនស្របច្បាប់របស់តុលាការយោធា ។ ការជំនុំជម្រះបែបនេះដែលត្រូវបានអនុវត្តឡើងដោយស្របទៅតាមបទដ្ឋានត្រឹមត្រូវនៃដំណើរការសបស្របនៃច្បាប់នេះ អាចនឹងមានផលប៉ះពាល់ជាវិជ្ជមានមួយមកលើតុលាការក្នុងស្រុក ។ យ៉ាងណាមិញ ខណៈពេលដែលការវិនិច្ឆ័យនេះគឺត្រឹមត្រូវតាមទស្សនៈផ្នែកច្បាប់ក៏ពិតមែនក៏ប៉ុន្តែ យើងអាចយល់បានថាជនរងគ្រោះប្រហែលជាមានអារម្មណ៍មិនពេញចិត្តទៅនឹងលទ្ធផលនេះនោះទេ ។ ផ្នែកខ្លះនៃការងាររបស់យើងគឺត្រូវធ្វើការជាមួយនឹងផ្នែកកិច្ចការ

ធារសាធារណៈដើម្បីធ្វើការផ្សព្វផ្សាយព័ត៌មាន និងធ្វើការពន្យល់ថា ទ្រឹស្តីយុត្តិធម៌គឺមានរួមបញ្ចូលទាំងការគោរពសិទ្ធិជនចុងចោទទៀតផង ។

CTM : មានឯកសារជាច្រើនត្រូវបានបង្រ្កងឡើង ទាក់ទងនឹងការខ្វែងគំនិតគ្នារវាងសហព្រះរាជអាជ្ញាជាតិនិងអន្តរជាតិជុំវិញបញ្ហាដីកាបញ្ជូនរឿងទៅជំនុំជម្រះបន្ថែម បន្ទាប់ពីសំណុំរឿង ០០២នេះ ។ ថាតើខាងព្រះរាជអាជ្ញាជាតិនិងអន្តរជាតិនឹងធ្វើការសហការគ្នាដោយរបៀបណា ប្រសិនបើពិតជាមានចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះបន្ថែមមែននោះ?

ជា លាង : ការស៊ើបអង្កេតចេញពីការិយាល័យសហចៅក្រមស៊ើបអង្កេត គួរតែត្រូវបានធ្វើឡើងដោយចៅក្រមអន្តរជាតិក៏ដូចជាចៅក្រមជាតិផងដែរ ។ ថ្មីៗនេះមានតែចៅក្រមអន្តរជាតិប៉ុណ្ណោះដែលកំពុងធ្វើការស៊ើបអង្កេតនេះ ហើយខ្ញុំមិនយល់ឃើញថាអង្គជំនុំជម្រះអាចដំណើរការជំនុំជម្រះក្តីជាមួយនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលគ្រាន់តែត្រូវបានចុះហត្ថលេខាដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិតែម្នាងនោះបានទេ ។ យើងបានប្រឆាំងទៅនឹងការដាក់ជូននូវដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម ហើយយើងនឹងធ្វើការប្រឆាំងទៅនឹងរាល់ដីការដំណោះស្រាយទាំងឡាយណា ដែលមិនត្រូវបានចុះហត្ថលេខាដោយចៅក្រមទាំងសងខាងឡើយ ។ យើងមិនបានចូលរួមនៅក្នុងការស៊ើបអង្កេតបឋមនោះទេ ដូច្នោះថាតើយើងអាចទទួលយកដីកាបញ្ជូនរឿងទៅជំនុំជម្រះនោះដោយរបៀបណាដែលថាទាំងខាងការិយាល័យរបស់ខ្ញុំនិងការិយាល័យសហចៅក្រមស៊ើបអង្កេតជាតិមិនបានពាក់ព័ន្ធនៅក្នុងការប្រមូលភ័ស្តុតាងផងនោះ?